00622324

លេខ/No: D427/5/5

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៥២) |
| **ដាក់ទៅ** | : | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | : | ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១០ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | អង់គ្លេស |

**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 08 / 11 / 2010
ម៉ោង (Time/Heure): 15:55
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ / Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងដីកាដំណោះស្រាយ**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY
លោក យ៉េត ចរិយា
លោក William SMITH
លោក សេង ប៊ុនឃាង
លោក ច័ន្ទ តារាស្មី
លោក Anees AHMED

**អ្នកទទួលឯកសារ:**

**អង្គបុរេជំនុំជម្រះ:**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING, QC
ចៅក្រម ន័យ ថុល
ចៅក្រម Catherine Marchi-Uhel
ចៅក្រម ហួត វុទ្ធី

**មេធាវីដើមបណ្តឹងឧទ្ធរណ៍:**
លោក អាង ឧត្តម

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី:**
លោក គឹម ម៉េងឃី
កញ្ញា ម៉ុច សុវណ្ណារី
លោកស្រី Martine JACQUIN
លោក Philippe CANONNE
លោកស្រី Elizabeth RABESANDRATANA
លោកស្រី Annie DELAHAIE
លោកស្រី Fabienne TRUSSES-NAPROUS
លោក នី ចាន់ឌី

*បណ្ដឹងឧទ្ធរណ៍លេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៥២)*

លោក MichaelG.KARNAVAS

**មេធាវីការពារក្ដីដទៃទៀត:**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor KOPPE

លោក ផាត់ ពៅស៊ាង

កញ្ញា Diana ELLIS

លោក ស សូវាន

លោក Jacques VERGÈS

លោក Philippe GRECIANO

លោក ឡោ ជុនធី

កញ្ញា SILKE Studzinsky

លោក គង់ ពិសី

លោក ហុង គឹមសួន

លោក យុង ផានិត

លោកស្រី ស៊ីន សុវ៉ន

លោក Mahdev MOHAN

លោកស្រី NGUYEN Lyma

កញ្ញា Marie GUIRAUD

លោក Patrick BAUDOUIN

លោក Olivier BAHOUGNE

## ក. សេចក្តីផ្តើម

១. ដើមបណ្តឹងឧទ្ធរណ៍ អៀង សារី បានដាក់បណ្តឹងឧទ្ធរណ៍មួយ ("បណ្តឹងឧទ្ធរណ៍")[1] ស្វែងរកការកែប្រែដីការបស់សហចៅក្រមស៊ើបអង្កេត ("ការនៅបន្តក្នុងសេចក្តីសម្រេចនៃការឃុំខ្លួន")[2] ដើម្បីបន្តការឃុំខ្លួនបណ្តោះអាសន្នរបស់គាត់ រហូតដល់គាត់ត្រូវបាននាំខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[3]។ ដើមបណ្តឹងឧទ្ធរណ៍អះអាងថាៈ (១) សហចៅក្រមស៊ើបអង្កេត ខកខានមិនបានអនុវត្តតាមលក្ខខណ្ឌតម្រូវនៃវិធាន៦៨ ដែលថា ការបន្តការឃុំខ្លួនបណ្តោះអាសន្នត្រូវមានភាពជាក់លាក់ និងសំអាងហេតុ និង (២) ទោះបីដីកាសម្រេចនេះបានបំពេញតាមលក្ខខណ្ឌទាំងនេះក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេត មានកំហុសឆ្គងនៅក្នុងការសម្រេច ដែលថាការបន្តការឃុំខ្លួន គឺជាការចាំបាច់[4]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តយ៉ាងត្រឹមត្រូវចំពោះវិធានផ្ទៃក្នុង និងច្បាប់ អ.វ.ត.ក នៅក្នុងការអនុវត្តអំណាចរបស់ខ្លួន នៅក្រោមវិធាន៦៨ ដើម្បីរក្សាបន្តការឃុំខ្លួនបណ្តោះអាសន្នលើដើមបណ្តឹងឧទ្ធរណ៍ រហូតដល់រូបគាត់ត្រូវបាននាំខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ សហព្រះរាជអាជ្ញា សូមស្នើឱ្យអង្គបុរេជំនុំជម្រះបដិសេធចោលបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការនៅបន្តសេចក្តីសម្រេចក្នុងការឃុំខ្លួននេះ ដោយសារមូលហេតុដូចតទៅៈ

(ក) ក្នុងការរក្សាការបន្តការឃុំខ្លួនបណ្តោះអាសន្នលើដើមបណ្តឹងឧទ្ធរណ៍ សហចៅក្រមស៊ើបអង្កេតបានគោរព និងអនុវត្តតាមយ៉ាងត្រឹមត្រូវតាមវិធាន ៦៣.៣ និងវិធាន ៦៨.១ នៃវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក; ហើយ

(ខ) ដើមបណ្តឹងឧទ្ធរណ៍ខកខានមិនបានបង្ហាញឱ្យឃើញអំពី "ការប្រែប្រួលនៃកាលៈទេសៈ" ដែលជាការអនុញ្ញាតឱ្យមានការពិនិត្យឡើងវិញ លើភាពចាំបាច់នៃការឃុំខ្លួនរូបគាត់។

២. ក្នុងសេចក្តីសម្រេចដាច់ដោយឡែកមួយ ដែលបានដាក់បញ្ចូលនៅក្នុងដីកាដំណោះស្រាយសម្រាប់សំណុំរឿងលេខ០០២ សហចៅក្រមស៊ើបអង្កេតបានបញ្ជាឱ្យ "ជនជាប់ចោទស្ថិតនៅបន្តឃុំខ្លួនជា

---

[1] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងដីកាដំណោះស្រាយ, សំណុំរឿងលេខៈ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៥២), ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០, ឯកសារលេខៈ D427/5/1 ("បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនក្នុងដីកាដំណោះស្រាយ") ។

[2] ដីកាដំណោះស្រាយ, សំណុំរឿងលេខៈ ០០២/១៩-០៩-២០០៧-អវតក/កសចស, ការិយាល័យសហចៅក្រមស៊ើបអង្កេត, ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០, ឯកសារលេខ: D427 ("ដីកាដំណោះស្រាយ"), កថាខណ្ឌទី១៦២២-១៦២៤ ។

[3] ដីកាដំណោះស្រាយ, កថាខណ្ឌទី១៦២៤ ។

[4] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនក្នុងដីកាដំណោះស្រាយ, កថាខណ្ឌទី១ ។

បណ្តោះអាសន្ន រហូតដល់ពួកគេត្រូវបាននាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង"[5]។ ដោយមានការកត់សំគាល់លើវិធាន ៦៣, ៦៤, ៦៦, ៦៨ និង ៨២, សហចៅក្រមស៊ើបអង្កេត បានផ្តល់សំអាងហេតុថា៖

> យល់ឃើញថា ដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងដីកាដំណោះស្រាយនេះ ក្នុងការគាំទ្រដល់ការបញ្ជូន នួន ជា, អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ទៅជំនុំជម្រះ លក្ខខណ្ឌដែលបានកំណត់ដោយវិធាន ៦៣.៣.ក នៃវិធានផ្ទៃក្នុងត្រូវបានបំពេញ។
>
> យល់ឃើញ(បន្ថែមទៀត)ថា ទាក់ទិននឹងលក្ខខណ្ឌដែលតម្រូវដោយវិធាន ៦៣.៣.ខ នៃវិធានផ្ទៃក្នុង សំអាងហេតុនៃដីកាសម្រេចបន្តការឃុំខ្លួនបណ្តោះអាសន្ន នួន ជា ចុងក្រោយ (ដែលមិនត្រូវបានប្តឹងឧទ្ធរណ៍) ហើយសាលដីកាចុងក្រោយរបស់អង្គបុរេជំនុំជម្រះ ដែលសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន នៅតែរក្សាតម្លៃរបស់ខ្លួនដដែល ហើយចំណុចថ្មីដែលមានតែមួយគត់គឺ ការចោទប្រកាន់ទៅលើអ្នកទាំងនោះ ដែលនេះរឹតតែធ្វើឱ្យសំអាងហេតុដែលមាននៅក្នុងដីកាកន្លងមក កាន់តែមានលក្ខណៈរឹងមាំ និងធ្វើឱ្យការឃុំខ្លួនរឹតតែមានភាពចាំបាច់ជាងពេលណាៗទាំងអស់។
>
> ទន្ទឹមគ្នានេះដែរ យល់ឃើញថា ការបន្តការឃុំខ្លួនជនជាប់ចោទរហូតដល់ពេលនាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយអនុវត្តតាមវិធាន៦៨ នៃវិធានផ្ទៃក្នុង [...][6]។

## ខ. សហចៅក្រមស៊ើបអង្កេតបានបំពេញ និងបានអនុវត្តយ៉ាងត្រឹមត្រូវនូវវិធាន៦៨

៣. វិធាន៦៨.១ នៃវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក ចែងថា៖

> ការចេញដីកាដំណោះស្រាយ មានអានុភាពបញ្ចប់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងដីកាសម្រេចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ នៅពេលដែលរយៈពេលកំណត់នៅក្នុងការប្តឹងឧទ្ធរណ៍ត្រូវផុតរលត់។ ប៉ុន្តែនៅពេលដែលសហចៅក្រមស៊ើបអង្កេត យល់ឃើញថា លក្ខខណ្ឌទាំងឡាយសម្រាប់បង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ឬឱ្យមានការត្រួតពិនិត្យតាមផ្លូវតុលាការក្រោមវិធាន ៦៣ និង ៦៥ នៅតែតម្រូវ សហចៅក្រមស៊ើបអង្កេតអាចសម្រេចបន្តឃុំជនជាប់ចោទបណ្តោះអាសន្នតទៅទៀត ឬរក្សាលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការចំពោះជនជាប់ចោទដដែល នៅក្នុងសេចក្តីសម្រេចមានសំអាងហេតុជាក់លាក់មួយដោយឡែក នៅក្នុងដីកា

---

[5] ដីកាដំណោះស្រាយ, កថាខណ្ឌទី១៦២៤ ។

[6] ដីកាដំណោះស្រាយ, កថាខណ្ឌទី១៦២២-១៦២៤ ។

ដំណោះស្រាយ រហូតដល់ជនជាប់ចោទនេះ ត្រូវបាននាំខ្លួនទៅជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង[7]។

៤. សហចៅក្រមស៊ើបអង្កេតបានបំពេញសព្វគ្រប់តាមវិធាន៦៨.១ នៃវិធានផ្ទៃក្នុង ចំពោះលក្ខខណ្ឌតម្រូវអំពី"ដីកាសម្រេចជាក់លាក់, ដោយមានបញ្ជាក់មូលហេតុ"។ ការរក្សាទុកក្នុងដីកាសម្រេចស្តីពីការឃុំខ្លួនដដែល ដែលត្រូវបានដាក់បញ្ចូលនៅក្នុងដីកាដំណោះស្រាយ គឺជាដីកាសម្រេចជាក់លាក់មួយ ដើម្បីឱ្យរក្សាទុកដើមបណ្តឹងឧទ្ធរណ៍នៅក្នុងការឃុំខ្លួនបណ្តោះអាសន្នដដែល។ លើសពីនេះ ដីកាសម្រេចជាក់លាក់នេះបានយោងដោយច្បាស់ៗទៅលើ "ភស្តុតាងនានាដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ"[8] -ដែលក្នុងនោះសហចៅក្រមស៊ើបអង្កេតបានរៀបរាប់យ៉ាងល្អិតល្អន់ជាងគេអំពីប្រវត្តិដើម តួនាទី និងការចូលរួមរបស់ដើមបណ្តឹងឧទ្ធរណ៍នៅក្នុងឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់[9]។ ដូចដែលសហចៅក្រមស៊ើបអង្កេតបានពន្យល់រួចហើយ "ការវែកញែកហេតុផល ដែលបានអនុម័តយកដោយអង្គបុរេជំនុំជម្រះនៅក្នុងដីកាសម្រេចចុងក្រោយបង្អស់របស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន គឺនៅមានអានុភាពដដែលទាំងស្រុង" ធាតុផ្សំដែលថ្មីគឺមានតែដីកាបញ្ជូន[ដើមបណ្តឹងឧទ្ធរណ៍]ទៅជំនុំជម្រះតែប៉ុណ្ណោះ ដែលគ្រាន់តែជួយពង្រឹងកម្លាំងដល់ហេតុផលសម្រាប់ការធ្វើសេចក្តីសម្រេចដូចដែលបានលើកឡើងពីខាងដើមតែប៉ុណ្ណោះ ហើយដែលនាំឱ្យការឃុំខ្លួនជាបន្តទៅទៀតមានភាពកាន់តែចាំបាច់ជាងនេះទៅទៀត"[10]។

៥. អង្គបុរេជំនុំជម្រះ និងការិយាល័យសហចៅក្រមស៊ើបអង្កេតបានសម្រេចជាដដែលៗ អនុលោមតាមវិធាន៦៣.៣.ក នៃវិធានផ្ទៃក្នុងថាមាន "មូលហេតុដែលត្រូវបានរកឃើញ និងដែលធ្វើឱ្យជឿជាក់យ៉ាងច្បាស់ថា[ដើមបណ្តឹងឧទ្ធរណ៍] ប្រហែលជាបានប្រព្រឹត្តនូវឧក្រិដ្ឋកម្មផ្សេងៗដូចការចោទប្រកាន់មកលើ[ខ្លួន]មែនហើយ"[11]។ ដីកាដំណោះស្រាយដែលចោទប្រកាន់លើដើមបណ្តឹងឧទ្ធរណ៍ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើបំពារបំពានផ្សេងៗលើអនុសញ្ញានានានៃទីក្រុងហ្សឺណែវ និងការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦[12]

[7] វិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិសោធនកម្មលើកទី៦, ចុះថ្ងៃទី១៧ កញ្ញា ២០១០ ("វិធាន"), វិធាន៦៨ ។

[8] ដីកាដំណោះស្រាយ កថាខណ្ឌទី១៦២២។

[9] *សូមអាន ឧទាហរណ៍ដូចជា* ដីកាដំណោះស្រាយ កថាខណ្ឌទី៩៩៤-១១២៥។

[10] ដីកាដំណោះស្រាយ, កថាខណ្ឌទី១៦២៣ (ដែលលើកសំអាងលើ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចស្តីពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី៣០ មេសា២០១០ , ឯកសារលេខ C22/9/14 (បណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួន), កថាខណ្ឌទី៣៣-៥៦)។

[11] បណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួន, កថាខណ្ឌទី១៧ (ដែលលើកសំអាងលើ សេចក្តីសម្រេចស្តីពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី១០ វិច្ឆិកា ២០០៨ , ឯកសារលេខ C22/4 (សេចក្តីសម្រេចស្តីពីការឃុំខ្លួនបណ្តោះអាសន្ន)។

[12] ដីកាដំណោះស្រាយ កថាខណ្ឌទី១៦១៣។

ដែលត្រូវបានស្តែងឡើងយ៉ាងទូលំទូលាយពី "មូលហេតុត្រូវបានរកឃើញ"[13]នោះ។ ក្នុងការរក្សាទុកនូវសេចក្តីសម្រេចស្តីពីការឃុំខ្លួនរបស់ខ្លួនដដែលនោះ សហចៅក្រមស៊ើបអង្កេត បានបញ្ជាក់ឱ្យដឹងពីយុត្តិសាស្ត្រកាលពីមុនៗរបស់ អវតក ថានៅតែមានអានុភាពដដែលទាំងស្រុង និងបានប្រើប្រាស់ សៀវភៅបញ្ជីសាលក្រមដែលមានបញ្ជាក់មូលហេតុទាំងនេះ ដើម្បីគាំទ្រដល់ដីកាសម្រេចរបស់ខ្លួន។ ហេតុដូចនេះ គឺសហចៅក្រមស៊ើបអង្កេតបានអនុវត្តស្របតាមលក្ខខណ្ឌតម្រូវនៅក្នុងវិធាន៦៨ នៃវិធានផ្ទៃក្នុងដែលថាដីកាសម្រេចឱ្យបន្តរក្សាទុកដើមបណ្តឹងឧទ្ធរណ៍នៅក្នុងការឃុំខ្លួនបណ្តោះអាសន្នដដែលត្រូវតែមានភាពជាក់លាក់ និងមានការបញ្ជាក់មូលហេតុ។ ហេតុដូចនេះ មែកធាងសំខាន់ទី១ នៃបណ្តឹងឧទ្ធរណ៍របស់ អៀង សារី គឺគ្មានមូលដ្ឋានទេ ហើយដែលត្រូវតែបដិសេធចោល។

## គ. មិនមានកាលៈទេសៈណាថ្មីដែលត្រូវបានលើកយកមកសំអាងដើម្បីប្រឆាំងជំទាស់នឹងការរកឃើញរបស់អង្គបុរេជំនុំជម្រះ និងរបស់សហចៅក្រមស៊ើបអង្កេតដែលថា ការឃុំខ្លួនគឺជាការចាំបាច់ឡើយ

៦. វិធាន៦៣(៣) នៃវិធានផ្ទៃក្នុងរបស់តុលាការចែងថា៖

> សហចៅក្រមស៊ើបអង្កេតអាចចេញដីកាសម្រេចឃុំខ្លួនជនត្រូវចោទបានតែក្នុងលក្ខណ្ឌដូចខាងក្រោម៖ (ក) មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើនដូចមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម (ខ) សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការដ៏ចាំបាច់ដើម្បី:
>
> (១) រារាំងកុំឱ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អវតក។
>
> (២) ថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង។
>
> (៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទ នៅក្នុងដំណើរការនីតិវិធី។
>
> (៤) ការពារសន្តិសុខឱ្យជនត្រូវចោទ ឬ
>
> (៥) រក្សាសណ្តាប់ធ្នាប់សាធារណៈ[14]។

៧. សហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាករណីលើកលែងមួយ ចំពោះវិធានទូទៅស្តីពីសេរីភាព នៅក្នុងដំណាក់កាលមុនការជំនុំជម្រះក្តី ហើយហេតុនេះ

---

[13] ដីកាដំណោះស្រាយ កថាខណ្ឌទី១៦២២ (" តាមស្មារតីនៃភស្តុតាងដូចដែលមានចែងនៅក្នុងដីកាដំណោះស្រាយនេះ គឺគាំទ្រឱ្យបញ្ជូន នួន ជា, អៀង សារី, អៀង ធីរិទ្ធ, និង ខៀវ សំផន ទៅជំនុំជម្រះ ដែលជាលក្ខខណ្ឌដែលមានចែងនៅក្នុងវិធាន៦៣.៣.ក នៃវិធានផ្ទៃក្នុងត្រូវបានបំពេញសព្វគ្រប់ [។]")។

[14] វិធានផ្ទៃក្នុងរបស់ អវតក, វិសោធនកម្មលើកទី៦, ចុះថ្ងៃទី១៧ កញ្ញា ២០១០, វិធាន៦៣.៣។

"ការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន អាចនឹងត្រូវបានរក្សាទុកដដែល បើសិនជាលក្ខខណ្ឌដូចដែលមានចែងនៅក្នុងវិធាន៦៣(៣) នៃវិធានផ្ទៃក្នុង នៅតែបំពេញបានដដែល"[15]។ គឺជាទម្លាប់អនុវត្តរបស់តុលាការនេះ ក្នុងការពិនិត្យមើលឡើងវិញពីលើវេទិកានៃការរកឃើញពីមុនៗដែលមានសុពលភាព និងពិនិត្យតែលើភស្តុតាងថ្មីៗតែប៉ុណ្ណោះ[16]។ បើសិនជាមិនមានកាលៈទេសៈប្រែប្រួលណាមួយច្បាស់លាស់ចាប់តាំងពីដីកាសម្រេចឃុំខ្លួនលើកមុនមក ដែលអាចនឹងនាំឱ្យធ្វើសេចក្តីសន្និដ្ឋានស្តីពីភាពចាំបាច់ក្នុងការឃុំខ្លួនផ្សេងពីនេះទេ នោះការឃុំខ្លួនបណ្តោះអាសន្ននៅតែត្រូវបានចាត់ទុកជាវិធានការចាំបាច់មួយតទៅទៀត[17]។

៨. អង្គបុរេជំនុំជម្រះ និងការិយាល័យសហចៅក្រមស៊ើបអង្កេត ធ្លាប់បានសម្រេចរួចហើយ ដោយអនុលោមតាមវិធាន ៦៣.៣.ខ ថាការឃុំខ្លួនដើមបណ្តឹងឧទ្ធរណ៍បណ្តោះអាសន្ន គឺជា "វិធានាការចាំបាច់មួយ ដើម្បីធានាវត្តមានរបស់ជនត្រូវចោទនៅក្នុងអំឡុងពេលនៃដំណើរការនីតិវិធី, ដើម្បីការពារសុវត្ថិភាពរបស់ជនត្រូវចោទ និងដើម្បីថែរក្សាសណ្តាប់ធ្នាប់សាធារណៈ"[18]។ សហចៅក្រមស៊ើបអង្កេត បានបញ្ជាក់សាជាថ្មីឡើងវិញនូវគោលជំហរនេះនៅក្នុងការក្សាទុកនូវសេចក្តីសម្រេចស្តីពីការឃុំខ្លួន ដោយបានពន្យល់ថា៖ "វាជាការចាំបាច់ក្នុងការរក្សាឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន រហូតដល់គេត្រូវបង្ហាញខ្លួន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីធានាពីវត្តមានរបស់ជនត្រូវចោទនៅពេលសវនាការ, ថែរក្សាសណ្តាប់ធ្នាប់សាធារណៈ និងបង្វៀងហានិភ័យរបស់ជនត្រូវចោទដែលដាក់សម្ពាធលើសាក្សី ឬជនរងគ្រោះ ឬមួយក៏បំផ្លាញភស្តុតាងចោលបើសិនជាត្រូវបានដោះលែង"[19]។ សហចៅក្រមស៊ើបអង្កេត មិនត្រូវបានគេតម្រូវឱ្យធ្វើការពិនិត្យគ្រប់ភស្តុតាងទាំងអស់*តាំងពីដំបូងទីមក* ដើម្បីរកឱ្យឃើញថាការឃុំខ្លួនបណ្តោះអាសន្នដែលត្រូវធ្វើបន្តទៀតនេះ ជាវិធានការចាំបាច់មួយនោះទេ។

៩. សេចក្តីសម្រេចឱ្យមានការឃុំខ្លួនបណ្តោះអាសន្ននេះ និងសេចក្តីសម្រេចនានាជាបន្តបន្ទាប់មកទៀត ទាំងចំពោះការពន្យារពេល និងទាំងចំពោះការរក្សាទុកនូវការឃុំខ្លួន ត្រូវបានគេរកឃើញនៅក្នុងការវាយតម្លៃមានសុពលភាពមួយ ទៅលើលក្ខណៈវិនិច្ឆ័យទាំងឡាយនៃវិធាន៦៣.៣។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ដើមបណ្តឹងឧទ្ធរណ៍ ខកខានមិនបានបង្ហាញពី "ការផ្លាស់ប្តូរនៅក្នុងកាលៈទេសៈ" ណាមួយដែលនឹងធ្វើឱ្យកើតមានឡើងនូវលក្ខខណ្ឌតម្រូវណាមួយ ដើម្បីធ្វើការពិនិត្យ

---

[15] សេចក្តីសម្រេចស្តីពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, កថាខណ្ឌទី១០។

[16] សេចក្តីសម្រេចស្តីពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, កថាខណ្ឌទី១៤។

[17] សេចក្តីសម្រេចស្តីពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, កថាខណ្ឌទី២២។

[18] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចបន្តឃុំខ្លួនបណ្តោះអាសន្ន, កថាខណ្ឌទី ៣៣ (ដោយបានលើកឡើងពី ដីកាសម្រេចបន្តឃុំខ្លួនបណ្តោះអាសន្ន) ។

[19] ដីកាដំណោះស្រាយ, កថាខណ្ឌទី ១៦២៤ ។

សាឡើងវិញពីភាពចាំបាច់នៃការឃុំខ្លួននេះ[20]។ សហចៅក្រមស៊ើបអង្កេត បានពន្យល់ថា៖ "ធាតុផ្សំថ្មីតែមួយគត់" រវាងសេចក្តីសម្រេចចុងក្រោយរបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងការពន្យារពេលឃុំខ្លួនដើមបណ្តឹងឧទ្ធរណ៍ជាបណ្តោះអាសន្ន (ខែមេសា ឆ្នាំ២០១០) ហើយនិងការរក្សាទុកនូវសេចក្តីសម្រេចស្តីពីការឃុំខ្លួន(ខែកញ្ញា ឆ្នាំ២០១០) នោះគឺ ការបញ្ជូនខ្លួនដើមបណ្តឹងឧទ្ធរណ៍ទៅជំនុំជម្រះ[21]។ ការញែកចេញពីគ្នានៃសំអាងហេតុទាំងពីរនេះ ដែលត្រូវបានដើមបណ្តឹងឧទ្ធរណ៍ដាក់បញ្ចូលទៅក្នុងបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននេះ ត្រូវបានអង្គបុរេជំនុំជម្រះច្រានចោល កាលពីដើមឆ្នាំនេះ[22]។ ដោយហេតុថា ដើមបណ្តឹងឧទ្ធរណ៍ "មិនបានដាក់នូវសំអាងហេតុ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយដែលបញ្ជាក់ថា [ការបន្តការឃុំខ្លួន គឺមិនចាំបាច់ទេ] នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬនៅចំពោះមុខអង្គបុរេជំនុំជម្រះ"[23] នោះសេចក្តីសន្និដ្ឋានចុងក្រោយនានារបស់អង្គបុរេជំនុំជម្រះ និងសហចៅក្រមស៊ើបអង្កេត ដែលពាក់ព័ន្ធនឹងភាពចាំបាច់ក្នុងការបន្តការឃុំខ្លួន គឺនៅតែមានជាដដែល។ ដើមបណ្តឹងឧទ្ធរណ៍ត្រូវតែអះអាងការពារនូវការផ្លាស់ប្តូរកាលៈទេសៈដ៏ច្បាស់លាស់មួយ ដែលធ្វើឱ្យសេចក្តីសន្និដ្ឋាននានាពីមុនរបស់អង្គជំនុំជម្រះនេះ មានភាពមិនត្រឹមត្រូវតាមលក្ខណៈច្បាប់ ឬមានការផ្លាស់ប្តូរ ពាក់ព័ន្ធទៅនឹងភាពចាំបាច់នៃការបន្តការឃុំខ្លួន ឬមួយក៏ត្រូវបង្ហាញពីភស្តុតាងថ្មីជាក់ស្តែងណាមួយ ដើម្បីឱ្យគេធ្វើការពិចារណា។ មានតែភស្តុតាងថ្មីជាក់ស្តែងដែលបញ្ជាក់ថាមានការផ្លាស់ប្តូរកាលៈទេសៈប៉ុណ្ណោះទេ ដែលជាការបញ្ជូនខ្លួនដើមបណ្តឹងឧទ្ធរណ៍ទៅជំនុំជម្រះ។ ការវិវត្តន៍នេះគ្រាន់តែពង្រឹងការរកឃើញថា ការបន្តឃុំខ្លួនគឺនៅតែជាការចាំបាច់។

១០. ខណៈដែលការពិចារណាដ៏សំខាន់មួយ នៅក្នុងការកំណត់ពីភាពត្រឹមត្រូវតាមច្បាប់នៃការបន្តការឃុំខ្លួន ការកន្លងហួសទៅនៃពេលវេលានៅក្នុងនោះ និងអំពីវាផ្ទាល់ គឺពុំមែនជាកត្តាមួយដែលបញ្ជាក់ពីការផ្លាស់ប្តូរកាលៈទេសៈដែលនឹងត្រូវធ្វើឱ្យរបកគំហើញនានាពីមុន មានភាពមិនត្រឹមត្រូវតាមលក្ខណៈច្បាប់ ឬមានការផ្លាស់ប្តូរដែលពាក់ព័ន្ធទៅនឹងលក្ខខណ្ឌនានា តាមវិធាន ៦៣.៣.ខ នោះទេ។ ស្រដៀងគ្នានេះដែរ ដោយសារមានភាពធ្ងន់ធ្ងរនៃការបញ្ជូនខ្លួនទៅជំនុំជម្រះនៅក្នុងដីកាដំណោះស្រាយ ហើយសេចក្តីសម្រេចរបស់អង្គបុរេ[illegible] និងសហចៅក្រមស៊ើបអង្កេតមិនអាចជំទាស់បានទាក់ទងទៅនឹងសណ្តាប់ធ្នាប់សាធារណៈ

[20] បណ្តឹងឧទ្ធរណ៍ស្តីពីកាបន្តថិរវេលានៃការឃុំខ្លួន, កថាខណ្ឌទី ៣៣-៣៤ (ដោយបានបញ្ជាក់ពីបមាណីនៃ "ការគ្មានការផ្លាស់ប្តូរ កាលៈទេសៈ") ។

[21] ដីកាដំណោះស្រាយ, កថាខណ្ឌទី ១៦២៣ (ដោយបានលើកឡើងពីបណ្តឹងឧទ្ធរណ៍ស្តីពីកាបន្តថិរវេលានៃការឃុំខ្លួន, កថាខណ្ឌទី ៣៣-៥៦)។

[22] ដើមបណ្តឹងឧទ្ធរណ៍លើកសំអាងជំទាស់នឹងការបន្តថិរវេលានៃការឃុំខ្លួននៅលើទឡ្ហីករណ៍ដែលថាវាពុំចាំបាច់ទេក្នុងការ៖ ទី១) "ធានាវត្តមានរបស់ អៀង សារី នៅពេលសវនាការ", ទី២) "ការពារសន្តិសុខរបស់ អៀង សារី", ឬមួយក៏ ទី៣) "ថែរក្សាសណ្តាប់ធ្នាប់សាធារណៈ" ។ បណ្តឹងឧទ្ធរណ៍ទៅនឹងដីកាដំណោះស្រាយស្តីពីកាបន្តថិរវេលានៃការឃុំខ្លួន, កថាខណ្ឌទី ១៤-១៨ ។ អង្គបុរេជំនុំជម្រះ បានច្រានចោលយ៉ាងច្បាស់លាស់នូវសំអាងនីមួយៗទាំងនេះ នៅក្នុងបណ្តឹងឧទ្ធរណ៍មួយពីមុនដាក់ដោយដើមបណ្តឹងឧទ្ធរណ៍ ។ បណ្តឹងឧទ្ធរណ៍ស្តីពីកាបន្តថិរវេលានៃការឃុំខ្លួន, កថាខណ្ឌទី ៣៥-៥៦ ។

[23] បណ្តឹងឧទ្ធរណ៍ស្តីពីកាបន្តថិរវេលានៃការឃុំខ្លួន, កថាខណ្ឌទី ៥៦ ។

ត្រូវតែនាំទៅដល់ការធ្វើសេចក្ដីសន្និដ្ឋានតែមួយគត់ដែលថាការញែកចេញពីគ្នាទីពីរ នៃបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី គឺមិនមានអង្គសេចក្ដីទេ ហើយត្រូវបានខកខាន។

## ឃ. សេចក្ដីសន្និដ្ឋាន

១១. សហព្រះរាជអាជ្ញាស្នើឲ្យ អង្គបុរេជំនុំជម្រះប្រកាន់យកនូវការរក្សាទុកនូវសេចក្ដីសម្រេចស្ដីពីការឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេត ពីព្រោះដើមបណ្ដឹងឧទ្ធរណ៍ខកខានមិនបានបង្ហាញថា៖ ទី១) សហចៅក្រមស៊ើបអង្កេតមិនបានអនុវត្តឲ្យត្រូវតាមវិធាន ៦៨, ឬមួយក៏ ទី២) មានការផ្លាស់ប្ដូរកាលៈទេសៈដ៏ច្បាស់លាស់ណាមួយ ដែលបានប្រាប់ជាព័ត៌មានដល់សេចក្ដីសន្និដ្ឋាននានាពីមុនរបស់អង្គបុរេជំនុំជម្រះ ឬរបស់សហចៅក្រមស៊ើបអង្កេត អំពីភាពចាំបាច់នៃការបន្ដការឃុំខ្លួនដើមបណ្ដឹងឧទ្ធរណ៍៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១០ | **លោក យ៉េត ចរិយា**<br>**សហព្រះរាជអាជ្ញារង** | | |
| | **លោក William SMITH**<br>**សហព្រះរាជអាជ្ញារង** | | |